# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រុមហ៊ុនៈ ថ្មរូង ឌីវេឡុបមេន

## កិច្ចព្រមព្រៀង ស្តីអំពី

**ការព្យួរកិច្ចសន្យាការងារចំនួន០២ខែ ដែលបណ្តាលមកពីផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩**

យោងតាមស្ថានភាព ពីការរីករាលដាលនៃជំងឺកូវីដ-១៩ ពុំទាន់មានការថមថយ ជាហេតុធ្វើអោយពុំមានភ្ញៀវទេសចរណ៍ដើរកំសាន្ត និងមកស្នាក់នៅរមណីយដ្ឋានយើង អាស្រ័យហេតុនេះ ក្រុមហ៊ុន **ថ្មរូង ឌីវេឡុបមេន** សម្រេចព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន២ខែ ចាប់ពីថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២០។

ចំនួនកម្មករនិយោជិតសរុប ១០៥នាក់ ស្រី២៣នាក់ ចំនួនកម្មករនិយោជិតព្យួរកិច្ចសន្យាការងារមានចំនួនសរុប ៨៥នាក់ ស្រី២១នាក់។

ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ ក្រុមហ៊ុន **ថ្មរូង ឌីវេឡុបមេន** សម្រេចទូទាត់អោយកម្មករនិយោជិតដូចខាងក្រោម÷

១- សំរាប់ខែកញ្ញា ឆ្នាំ២០២០

- ៥០%នៃប្រាកបៀវត្ស សំរាប់បុគ្គលិកដែលព្យួរកិច្ចសន្យាការងារ១ខែ (អតិបរមា១,០០០ដុល្លារ និងអប្បបរមា ១០០ដុល្លាចំពោះបុគ្គលិកដែលមានប្រាក់បៀវត្ស<=២០០ដុល្លារ និង អប្បបរមា១៥០ដុល្លារចំពោះបុគ្គលិកដែលមានប្រាក់បៀវត្ស>២០០ដុល្លារ)។
- ៧៥%នៃប្រាកបៀវត្ស សំរាប់បុគ្គលិកដែលធ្វើការ៣សប្តាហ៍(អតិបរមា១,០០០ដុល្លារ និងអប្បបរមា ១៥០ដុល្លារ)។

២- សំរាប់ខែតុលា ឆ្នាំ២០២០

- ក្រុមហ៊ុននឹងផ្អាកទូទាត់ប្រាក់បៀវត្ស សំរាប់បុគ្គលិកដែលព្យួរកិច្ចសន្យាការងារ។
- ៧៥%នៃប្រាកបៀវត្ស សំរាប់បុគ្គលិកដែលធ្វើការ៣សប្តាហ៍(អតិបរមា១,០០០ដុល្លារ និងអប្បបរមា ១៥០ដុល្លារ)។

ប្រាក់បៀវត្សនិងត្រូវបើកជូនកម្មករនិយោជិតរៀងរាល់ថ្ងៃទី៣០នៃខែនីមួយៗ ។

ព្រះសីហនុ ថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០២០

តំណាងនិយោជិត

ជយ បញ្ញា ឆាយ អូនទូច នួន វិសាល

នាយក

ព្រះរាជាណាចក្រកម្ពុជា ថ្មរូង ឌីវេឡុបមេន TMOR RUNG DEVELOPMENT Co.,Ltd.